# សន្និសីទនិស្សិត ជំរុញឲ្យនិស្សិតចូលរួមស្រាវជ្រាវលើបញ្ហាផ្សេងៗនៅកម្ពុជា និងក្នុងតំបន់

By **ញឹក ស្រីលក្ខ (Nhek Sreyleak)**, thmeythmey.com
July 1st, 2017

សន្និសីទនិស្សិត ជាការរៀបចំវេទិកាមួយ សម្រាប់និស្សិតនៅតាមសាកលវិទ្យាល័យនានាក្នុងប្រទេសកម្ពុជា និងនិស្សិតក្នុងតំបន់ ឲ្យមានការចូលរួមស្រាវជ្រាវ និងធ្វើបទបង្ហាញ ដើម្បីទទួលមតិកែលម្អឲ្យមានភាពល្អប្រសើរ។ ជាពិសេសវេទិកានេះ មានអ្នកជំនាញ ផ្តល់ជាមតិដល់និស្សិត ផ្តោតទៅលើប្រធានបទនីមួយៗ ដែលពួកគេបានសិក្សាស្រាវជ្រាវ។ សន្និសីទនេះ រៀបចំនៅសាកលវិទ្យាល័យហ្សាម៉ាន់ ថ្ងៃទី០១ ខែកក្កដា។

សន្និសីទនេះ មាននិស្សិតចូលរួមមកពីសាកលវិទ្យាល័យចំនួន ៨ ក្នុងនិងក្រៅប្រទេស មានចំនួន ៣០នាក់។ ជាមួយគ្នានេះ និស្សិតទាំងនោះ មកពីប្រទេសចំនួន ៦ ក្នុងតំបន់រួមទាំងកម្ពុជា មានដូចជា ប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន ម៉ាឡេស៊ី ជប៉ុន និងប្រទេសវៀតណាម។




សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យហ្សាម៉ាន់ លោក ដេត សុខឧត្តម បានមានប្រសាសន៍ថា៖ «កម្មវិធីនេះ ជាការផ្ដល់ឱកាសដល់និស្សិតបង្ហាញការស្រាវជ្រាវ និងទទួលយកមតិកែលម្អផ្សេងៗ។ ម្យ៉ាងទៀត ចង់ឲ្យនិស្សិតមានទំនាក់ទំនងជាមួយគ្នា រវាងនិស្សិតកម្ពុជា និងនិស្សិតបរទេស ដើម្បីងាយស្រួលក្នុងការស្រាវជ្រាវនាពេលអនាគត»។

លោក សុខឧត្តម បានបន្ថែមថា កន្លងមកសន្និសីទថ្នាក់ជាតិ ថ្នាក់តំបន់ បានរៀបចំច្រើននៅកម្ពុជា សម្រាប់តែសាស្ត្រាចារ្យប៉ុណ្ណោះ ប៉ុន្តែសម្រាប់និស្សិតមិនសូវមាននោះទេ។ លោកបន្តថា ការរៀបចំសន្និសីទនេះ ក៏ជាការលើកទឹកចិត្តដល់និស្សិតវ័យក្មេងឲ្យចេះស្រាវជ្រាវ និងចែករំលែកលទ្ធផលដែលពួកគេរកឃើញផងដែរ។ សាកលវិទ្យាធិការរូបនេះ ជំរុញឲ្យនិស្សិតចូលរួមឲ្យបានច្រើន ដើម្បីស្រាវជ្រាវបញ្ហាផ្សេងៗ និងចែករំលែកចំណេះដឹង។ លោក សុខឧត្តម បញ្ជាក់ថា វេទិកានេះ មិនមែនសម្រាប់និស្សិតសាកលវិទ្យាល័យហ្សាម៉ាន់នោះទេ ប៉ុន្តែគឺចង់ឲ្យមានការចូលរួមពីនិស្សិតនៅតាមសាកលវិទ្យាល័យនានានៅកម្ពុជាផងដែរ។

គួរបញ្ជាក់ថា ក្នុងសន្និសីទនេះ មានប្រធានបទដែលនិស្សិតស្រាវជ្រាវចំនួន ៥ រួមមានបញ្ហាសេដ្ឋកិច្ចនៅកម្ពុជា និងដំណោះស្រាយ, ការប្រឈមក្នុងសង្គម នាសតវត្សទី២១, ទំនាក់ទំនងអន្តរជាតិអាស៊ី, ទេសចរណ៍ក្នុងយុគ្គសម័យសកលភាវូបនីយកម្ម និងការអប់រំ

សេដ្ឋកិច្ច ក្នុងសម័យសកលភាវូបនីយកម្ម។ សន្និសីទនិស្សិតប្រចាំឆ្នាំ២០១៧នេះ ជាវេទិកាលើកទី៩ហើយ ដែលសាកលវិទ្យាល័យ ហ្សាម៉ាន់ បានរៀបចំ ដោយផ្តល់ឱកាសដល់និស្សិតកម្ពុជា និងនិស្សិតបរទេស ដើម្បីលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍ៕